# លោកស្រី ភីឡៃ៖ ការរឹតត្បិតថ្មីៗលើNGOs កំពុងធ្វើឲ្យអន្តរាយដល់សិទ្ធិមនុស្ស

ទីក្រុងហ្សឺណែវ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ - លោកស្រី **ណាវី ភីឡៃ** ឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស កាលពីថ្ងៃពុធកន្លងទៅ បានសម្តែងកង្វល់យ៉ាងខ្លាំងចំពោះនិន្នាការបច្ចុប្បន្ន ឬកាលពីពេលថ្មីៗ នៅក្នុងប្រទេសមួយចំនួន ក្នុងការកាត់បន្ថយសេរីភាពរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងតួរអង្គសង្គមស៊ីវិលផ្សេងៗទៀត ដើម្បីប្រតិបត្តិការងារដោយឯករាជ្យ និងមានប្រសិទ្ធិភាព។

លោកស្រី **ភីឡៃ** បានមានប្រសាសន៍ថា " សេចក្តីព្រាងច្បាប់ស្តីពីNGOs នៅប្រទេស អេហ្ស៊ីព "ប្រសិនបើត្រូវបានអនុម័តនៅក្នុងទម្រង់បច្ចុប្បន្ននេះ នឹងធ្វើឲ្យអន្តរាយយ៉ាងធ្ងន់ធ្ងរដល់ស្មារតីបដិវត្តរបស់អេហ្ស៊ីព ដែលក្នុងនោះសង្គមស៊ីវិលបានដើរតួនាទីដ៏សំខាន់"។ វានឹងផ្តល់ឲ្យរដ្ឋាភិបាលនូវអំណាចដ៏លើសលប់ក្នុងការធ្វើនិយតកម្ម ត្រួតពិនិត្យ និងរឹតត្បិតលើការងាររបស់អង្គការសង្គមស៊ីវិលនានា។

លោកស្រីបានជម្រុញឲ្យអាជ្ញាធរប្រទេសអេហ្ស៊ីពឲ្យដកយកច្បាប់នោះចេញ ដោយលោកស្រីបានពិពណ៌នាថាជា "ការវាយប្រហារយ៉ាងធ្ងន់ធ្ងរដ៏មានសក្តានុពលមួយទៅលើសេចក្តីប្រាថ្នារបស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលប្រជាពលរដ្ឋអេហ្ស៊ីពទាំងឡាយបានតស៊ូទាមទារអស់ពេលដ៏យូរ និងមានលះបង់ដ៏ធំធេង។"

លោកស្រី **ភីឡៃ** បានកត់សំគាល់ថា សេរីភាពខាងសមាគម កំពុងកាន់តែស្ថិតក្រោមសម្ពាធ ដែលចេះតែកើនឡើងក្នុងប្រទេសជាច្រើននៅទូទាំងពិភពលោក។ លោកស្រីបន្តទៀតថា "សេរីភាពខាងសមាគមគឺជាសរសៃឈាមរបស់NGOs"។ "ការប៉ុនប៉ងតាមច្បាប់ ឬវិធានរដ្ឋបាលជាប្រព័ន្ធនានា ដើម្បីកាត់បន្ថយសកម្មភាពរបស់ពួកគេ អាចជាមហន្តរាយដ៏ធ្ងន់ធ្ងរ។"

លោកស្រីឧត្តមស្នងការបានលើកឡើងអំពីច្បាប់ថ្មីៗ ឬសេចក្តីស្នើច្បាប់ថ្មី និងវិធានការផ្សេងៗទៀត នៅក្នុងប្រទេសមួយចំនួនតាមកំរិតខុសៗគ្នា ដែលដាក់ការរឹតត្បិតថ្មីៗទៅលើសិទ្ធិសេរីភាពខាងសមាគម ដោយលើកយកឧទាហរណ៍ថា កាលពីខែកុម្ភៈអាជ្ញាធរថ្នាក់ខេត្តនានាក្នុងប្រទេស ហ្ស៊ីមបាវ៉េបានបញ្ជាឲ្យព្យួរសកម្មភាពរបស់NGOsចំនួន២៩។

លោកស្រីក៏បានចង្អុលផងទៅលើច្បាប់ដែលបានស្នើឡើងនៅកម្ពុជា ដែលនឹងអនុញ្ញាតឲ្យអង្គនីតិប្រតិបត្តិដើម្បីបិទNGOsមួយចំនួន ប្រសិនបើសកម្មភាពរបស់ពួកគេត្រូវបានយល់ឃើញថា " ធ្វើឲ្យប៉ះពាល់ដល់.... ការបង្រួបបង្រួមជាតិ វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីរបស់សង្គមជាតិកម្ពុជា។" ពុំមាននីតិវិធីប្តឹងតវ៉ាប្រឆាំងនឹងសេចក្តីសម្រេចបែបនេះនោះទេ។ លោកស្រី បានស្វាគមន៍ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការដាក់សេចក្តីព្រាងច្បាប់នេះស្ថិតក្រោមកិច្ចពិគ្រោះយោបល់ និងពិនិត្យឡើងវិញបន្ថែមទៀត។

នៅប្រទេសអាល់ជីរៀ ច្បាប់ថ្មីមួយចែងថា កម្មវត្ថុនិងគោលដៅនៃសកម្មភាពរបស់សមាគម មិនត្រូវផ្ទុយនឹង "តំលៃរបស់ជាតិ" ឡើយ។ ប្រសិនបើសមាគមនានា ពុំគោរពតាមបទប្បញ្ញត្តិនេះ ពាក្យស្នើសុំចុះបញ្ជីរបស់

ពួកគេ អាចនឹងត្រូវបដិសេធ។ ប្រសិនបើពួកគេ "ជ្រៀតជ្រែកជាមួយកិច្ចការផ្ទៃក្នុងជាតិ" ពួកគេអាចនឹងត្រូវព្យួរសកម្មភាព ឬរំលាយចោល។

លោកស្រីឧត្តមស្នងការបានមានប្រសាសន៍ថា "សង្គមស៊ីវិល រាប់បញ្ចូលទាំង NGOs សហជីព អ្នកការពារសិទ្ធិមនុស្ស បញ្ញាវន្ត អ្នកសារព័ត៌មាន bloggers និងអ្នកផ្សេងៗទៀត ដើរតួនាទីដ៏សំខាន់បំផុតក្នុងការធានាថា សិទ្ធិមនុស្សត្រូវបានការពារនៅក្នុងរដ្ឋនីមួយៗ"។ "សង្គមស៊ីវិលដ៏ស្វាហាប់និងស្វ័យ័ត ដែលអាចធ្វើប្រតិបត្តិការដោយសេរី គឺជាប្រព័ន្ធត្រួតពិនិត្យតុល្យភាពជាមូលដ្ឋានមួយ ( check and balance) ដែលចាំបាច់សម្រាប់កសាងសង្គមមួយឲ្យមានសុខមាលភាព ហើយជាស្ពានដ៏សំខាន់មួយសម្រាប់តភ្ជាប់រវាងរដ្ឋាភិបាលនិងប្រជាពលរដ្ឋ។ ហេតុដូច្នេះ វាជាប្រការចាំបាច់ណាស់ដែល NGOs អាចបំពេញតួនាទីត្រឹមត្រូវនៅក្នុងប្រទេសដែលស្ថិតក្នុងសម័យអន្តរកាល ក៏ដូចជាប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យរួចហើយ។"

លោកស្រី **ភីឡៃ** បានមានប្រសាសន៍ថា "តួរអង្គសង្គមស៊ីវិលនានាជួយប្រមូលគៀងគរប្រជាពលរដ្ឋឲ្យចូលរួមធ្វើការសម្រេចចិត្តនានាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។ ដោយមូលនេះហើយបានជាអង្គការសហប្រជាជាតិ ចាត់ទុកថាការចូលរួមចំណែករបស់ពួកគេ គឺមានតម្លៃ ទាំងក្នុងការបង្កើតគោលនយោបាយ និងក្នុងប្រតិបត្តិនៅតាមតំបន់។" "ប្រសិនបើការចូលរួមចំណែករបស់ពួកគេ មានភាពទន់ខ្សោយ ឬត្រូវបានរឹតត្បិតនោះ តម្រូវការផ្សេងៗរបស់ប្រជាពលរដ្ឋសាមញ្ញត្រូវបានគេមើលរំលោងយ៉ាងងាយស្រួលបំផុត ហើយជាពិសេស តម្រូវការរបស់ប្រជាពលរដ្ឋដែលត្រូវគេរើសអើងបំផុតនៅក្នុងសង្គមណាមួយ។"

លោកស្រី **ភីឡៃ** បានសម្តែងកង្វល់ចំពោះការប៉ុនប៉ងថ្មីៗ ឬដែលកំពុងកើតមានឡើង នៅប្រទេសមួយចំនួន ក្នុងការរឹតបន្តឹងការត្រួតពិនិត្យលើNGOs ដោយធ្វើការរឹតត្បិតទៅលើប្រភពមូលនិធិរបស់ពួកគេ ហើយជាពិសេស មូលនិធិបរទេសដែលអង្គការសង្គមស៊ីវិលដ៏មានប្រសិទ្ធិភាពបំផុតមួយចំនួនពឹងអាស្រ័យលើទាំងស្រុង។

នៅប្រទេសអេស៊្យូពី អង្គការសិទ្ធិមនុស្សមួយចំនួន ត្រូវបានបង្ខំឲ្យបិទ ដោយសារច្បាប់ឆ្នាំ២០០៩ ហាមឃាត់សមាគមទាំងនោះមិនឲ្យទទួលលើសពី១០ភាគរយនៃធនធានសរុបពីបរទេស។

នៅប្រទេសបេឡារុស វិសោធនកម្មមួយទៅលើក្រមព្រហ្មទណ្ឌត្រូវបានសភាអនុម័តកាលពីខែតុលាឆ្នាំ២០១១ដោយរដ្ឋសភា ដោយដាក់ឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការទទួលយកជំនួយ ឬអំណោយពីបរទេស ដោយរំលោភលើច្បាប់បេឡារុស។ គេជឿថា វិសោធនកម្មនេះ នឹងដាក់កម្រិតដល់ប្រតិបត្តិការងាររបស់NGOs ជាសារវន្ត។ លើសពីនេះទៅទៀត វិសោធនកម្មផ្សេងៗទៀត ក៏ត្រូវបានផ្តួចផ្តើមដាក់ចេញទៅលើច្បាប់យ៉ាងហោចណាស់ចំនួនប្រាំបីផ្សេងទៀត ដែលអាចនឹងរឹតត្បឹតថែមទៀតដល់ការបំពេញតួនាទីរបស់អង្គការសង្គមស៊ីវិលនានា។

នៅប្រទេសអ៊ីស្រាអែល ច្បាប់ស្តីពីមូលនិធិបរទេសដែលទើបតែអនុម័តកាលពីពេលថ្មីៗ អាចនឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់អង្គការសិទ្ធិមនុស្សនានា ដោយតំរូវឲ្យពួកគេធ្វើរបាយការណ៍ល្អិតល្អន់ បង្ខំពួកគេប្រកាសអំពីការគាំទ្រផ្នែកហិរញ្ញវត្ថុពីបរទេសនៅក្នុងគ្រប់ការប្រាស្រ័យទាក់ទងជាសាធារណៈទាំងអស់ ហើយគម្រាម ដាក់ទណ្ឌកម្មធ្ងន់ធ្ងរសម្រាប់ការមិនអនុវត្តតាម។

នៅប្រទេសវិនីហ្សេអ៊ុឡា ច្បាប់អង្គការប្រឆាំងនឹងភេរវកម្មនិងឧក្រិដ្ឋកម្មមានអង្គការចាត់តាំងមួយ ត្រូវបានអនុម័តដោយរដ្ឋសភាក្នុងខែមករា ឆ្នាំ២០១២ ប៉ុន្តែពុំទាន់ត្រូវបានប្រធានាធិបតីចុះហត្ថលេខាប្រកាសជាច្បាប់នៅឡើយទេ។ ច្បាប់នេះបង្កើតឲ្យមាននិយមន័យដ៏ទូលំទូលាយមួយអំពី "អំពើភេរវកម្ម" ដែលអាចយកមកអនុវត្តដើម្បីធ្វើទៅជាធម្មារូបទៅលើសកម្មភាពនៃការតវ៉ា ឬការប្រឆាំងពីសង្គម។ ច្បាប់នេះក៏ដាក់NGOs ក្រោមការតាមដានជានិរន្តរបស់អង្គការរដ្ឋ និងដាក់ការរឹតត្បិតលើការផ្តល់មូលនិធិពីបរទេសផងដែរ។

រីឯនៅប្រទេសអេហ្ស៊ីព អាជ្ញាធរបាននឹងកំពុងរឹតបន្តឹងលើអង្គការសង្គមស៊ីវិល ដែលទទួលមូលនិធិពីបរទេស និងលើការដាក់បង្ហាញរូបភាពអវិជ្ជមានដោយសកម្មជនអេហ្ស៊ីព បាននាំឲ្យពួកគេទទួលរងនូវយុទ្ធនាការបង្ខូចឈ្មោះ គម្រាមកំហែង និងការបំភិតបំភ័យចកាន់តែខ្លាំងឡើង។

លោកស្រី **ភីឡៃ** បានលើកឡើងថា "សកម្មជនស្ត្រីនៅក្នុងប្រទេសមួយចំនួន គឺងាយទទួលរងគ្រោះពីយុទ្ធនាការបង្ខូចឈ្មោះនានា ដែលជានិច្ចកាលត្រូវបានរៀបចំឡើងដោយចេតនា ដើម្បីបញ្ចប់សកម្មភាពរបស់ពួកគេ"។ "ខ្ញុំយល់ឃើញថា នេះគឺជាកង្វល់យ៉ាងខ្លាំងនៅប្រទេសអាហ្វ្រិកខាងជើងនិងមជ្ឈឹមបូព៌ា ដែលទីនោះ ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់និងប្រកបដោយសេចក្តីក្លាហានមួយ ជាមួយនឹងបុរស ក្នុងការផ្តួលរំលំ ឬប្រឈមនឹងអ្នកដឹកនាំផ្តាច់ការរបស់ពួកគេ។ ខណៈដែលប្រទេសទាំងនេះបង្កើតច្បាប់ និងស្ថាប័នថ្មីៗជាច្រើន នោះវាជាការសំខាន់ណាស់ដែលពួកគេ មិនត្រូវធ្វើដូច្នេះដោយយកចិត្តទុកដាក់ទៅលើយេនឌ័រតែមួយហើយឲ្យតែយេនឌ័រតែមួយប៉ុណ្ណោះចូលរួមក្នុងដំណើរការអន្តរកាលនោះ។ ការបំពានដោយពាក្យសំដីនិងរូបកាយលើសមាជិកសង្គមស៊ីវិលជាស្ត្រី គឺជាសញ្ញាដំបូងដែលបង្ហាញថា ដំណើរការកំណែទម្រង់កំពុងងាកទៅរកភាពជូរចត់ហើយ។"

លោកប្រធានឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានមានប្រសាសន៍ថា " NGOs ត្រូវតែអាចធ្វើប្រតិបត្តិការការងារដោយសេរីដោយគ្មានការជ្រៀតជ្រែកពីអង្គនីតិប្រតិបត្តិ"។ "ពួកគេត្រូវតែត្រូវបានពិគ្រោះយោបល់ និងដាក់បញ្ចូលទៅក្នុងសេចក្តីសម្រេចគោលនយោបាយ ជាពិសេសនៅពេលរដ្ឋកំពុងធ្វើដំណើរកំណែទម្រង់ ឬអន្តរកាល។ ហើយពួកគេមិនត្រូវទទួលរងទណ្ឌកម្មសម្រាប់ការរិះគន់ ឬចោទសួរលើគោលនយោបាយនិងដំណើរប្រព្រឹត្តទៅរបស់រដ្ឋនោះទេ។ រដ្ឋាភិបាលនានា ត្រូវការយល់ដឹងថា កិច្ចសហការជាមួយសង្គមស៊ីវិល គឺមិនមែនជាសញ្ញានៃកម្សោយភាពនោះទេ។ វា គឺជាវិធីកសាងសង្គមឲ្យកាន់តែប្រសើរមួយប្រកបដោយការរួមបញ្ចូល គឺជាអ្វីមួយដែលរដ្ឋាភិបាលទាំងអស់គួរតែព្យាយាមធ្វើ ហើយវាគឺអ្វីមួយដែលពួកគេពុំអាចចាត់ចែងតែម្នាក់ឯងនោះដែរ។

លោកស្រីភីឡៃក៏បានចង្អុលបង្ហាញផងដែរថា សេរីភាពខាងសមាគម ត្រូវបានបានចែងក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិមួយចំនួន ដែលរួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា២០) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា២២) ដែលជាសន្ធិសញ្ញាចងកាតព្វកិច្ចដែលរដ្ឋចំនួន១៦៧បានផ្តល់សច្ចាប័ន រួមបញ្ចូលទាំងរដ្ឋនានាដែលត្រូវបានរៀបរាប់ពីខាងផងដែរ។

លោកស្រី **ភីឡៃ** បាននិយាយថា "ជាភ័ព្វសំណាងល្អ នៅក្នុងប្រទេសមួយចំនួន រួមបញ្ចូលទាំងប្រទេសដែលទើបតែប្រកាន់យកលទ្ធិប្រជាធិបតេយ្យមួយចំនួន សង្គមស៊ីវិល ត្រូវបានអនុញ្ញាតឲ្យបំពេញតួនាទីឲ្យអស់ពីលទ្ធភាពរបស់ពួកគេ ជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងសហការជាមួយរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិនានាដូចជាការិយាលOHCHRរបស់ខ្ញុំផងដែរ។ ជាអាទិ៍ នៅប្រទេសទុយណេស៊ី ការិយាល័យសិទ្ធិមនុស្សអ.ស.បឥឡូវនេះ មិនត្រឹមតែអាចមានវត្តមាននៅទីនោះជាលើកទីមួយនៅក្នុងប្រវត្តិសាស្រ្តប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងអាចកសាងទំនាក់ទំនងយ៉ាងជិតស្និតនិងរំភើប ជាមួយទាំងរដ្ឋាភិបាលនិងវិស័យសង្គមស៊ីវិលដែលទើបតែរីកដុះដាលរបស់ប្រទេសនេះផងដែរ។"

លោកស្រីឧត្តមស្នងការបន្តទៀតថា "ជាធម្មតាទេដែលមានភាពតានតឹងម្តងកាលក្នុងទំនាក់ទំនងរវាងសង្គមស៊ីវិលនិងអាជ្ញាធរ ប៉ុន្តែវាពុំចាំដាច់ទេសម្រាប់ភាពតានតឹងទាំងនេះ បង្កឲ្យក្លាយទៅជាការសង្ស័យគ្នាបដិបក្ខនិយម ឬការគាបសង្កត់ទាំងស្រុងពីសំណាក់អាជ្ញាធរ ដែលធ្វើឲ្យមានការគាបសង្កត់នោះ។" "ក្នុងរយៈពេលវែង ពុំមានអ្វីចំណេញនោះទេ ហើយនឹងបណ្តាលមានការបាត់បង់អត្ថប្រយោជន៍យ៉ាងច្រើនទៅវិញទេ នៅពេលដែលរដ្ឋព្យាយាមបង្ក្រាបសង្គមស៊ីវិលនោះ។"

ចប់

*សម្រាប់ព័ត៌មានបន្ថែម ឬសំណើរព័ត៌មាន សូមទំនាក់ទំនងអ្នកនាំពាក្យ Rupert Colville (+41 22 917 9767 / rcolville@ohchr.org) ឬ Ravina Shamdasani មន្ត្រីផ្នែកព័ត៌មាន (+ 41 22 917 9310 / rshamdasani@ohchr.org) និង Xabier Celaya (+ 41 22 917 9383 / xcelaya@ohchr.org).*

**ស្វែងរកព័ត៌មានពីអ.ស.ប សិទ្ធិមនុស្សនៅបណ្តាញទំនាក់ទំនងសង្គមៈ**

Facebook: https://www.facebook.com/unitednationshumanrights

Twitter: http://twitter.com/UNrightswire

YouTube: http://www.youtube.com/UNOHCHR

សូមមើលក្រមសិទ្ធិមនុស្សជាសកលតាមគេហទំព័រៈ http://uhri.ohchr.org/en